**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលខេត្តកំពង់ឆ្នាំង
លេខ ១៥៤ សសរ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ:..........
មកដល់ថ្ងៃទី.....ខែ.....ឆ្នាំ.....
ម៉ោង.....១០.០០.....

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ រដ្ឋបាលខេត្តកំពង់ឆ្នាំង ដើម្បីជំរុញការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ ២០១៥-២០១៨

### អភិបាលខេត្តកំពង់ឆ្នាំង

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០១ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៣ស្ដីពីការតែងតាំងអភិបាល នៃគណៈអភិបាល ខេត្តកំពង់ឆ្នាំង
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០៥០៨ /០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ ១៥២០ សជណ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ ២០១៥-២០១៨
- យោងតាមសំណូមពរចាំបាច់នៃការងារ

### <u>សម្រេច:</u>

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលខេត្តកំពង់ឆ្នាំងដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្ដម | **ឈួរ ច័ន្ទឌឿន** | អភិបាលខេត្ត | ប្រធាន |
| ២-លោក | **អម សុភា** | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣-លោក | **ខេន ផល្លី** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោក | **សៅ កៅ** | នាយកស្ដីទី ទីចាត់ការរដ្ឋបាលនៃសាលាខេត្ត | សមាជិក |
| ៥-លោក | **គង់ សុវណ្ណអស្ចារ្យ** | នាយកទីចាត់ការ ផែនការនិងវិនិយោគនៃសាលាខេត្ត | សមាជិក |
| ៦-លោក | **ម៉ុន វុត្ថា** | នាយកទីចាត់ការ ហិរញ្ញវត្ថុ នៃសាលាខេត្ត | សមាជិក |
| ៧-លោក | **យ៉ង់ វណ្ណា** | នាយកស្ដីទីទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលាខេត្ត | សមាជិក |

| | | | |
|---|---|---|---|
| ៨-លោក | **អ៊ុក ឌីម** | នាយកទីចាត់ការ អន្តរវិស័យនៃសាលាខេត្ត | សមាជិក |
| ៩-លោក | **ស្វាយ ទិត** | ប្រធានអង្គភាព លទ្ធកម្ម រដ្ឋបាលខេត្ត | សមាជិក |
| ១០-លោក | **អ៊ុំ ជួបកុសល** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១១-លោក | **ការុណ្ណុល ចិត្រា** | ប្រធានរតនាគារខេត្ត | សមាជិក |
| ១២-លោក | **អភិបាល** | ក្រុង ស្រុក | សមាជិក |
| ១៣-លោក | **សៅ សុខ** | ប្រធានការិ.ក្របខ័ណ្ឌនិងបណ្តុះបណ្តាល | មន្ត្រីបង្គោល |
| ១៤-លោក | **កេត សុភឿន** | មន្ត្រីការិ.ក្របខ័ណ្ឌនិងបណ្តុះបណ្តាល | មន្ត្រីបង្គោល |

**ប្រការ២ .-**

ក្រុមការងារនេះមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ក្នុងការគ្រប់គ្រងនិងដឹកនាំគ្រប់ការងារពាក់ព័ន្ធនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត។
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។
- សម្របសម្រួលនិងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ ។
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ។
- ផ្តល់កិច្ចសហការនិងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្ត។
- តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត។

**ប្រការ៣.-**

សេចក្តីសម្រេចពីមុនដែលមានខ្លឹមសារផ្ទុយពីនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយក នាយករងរដ្ឋបាលសាលាខេត្ត អភិបាលក្រុង ស្រុក នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះសាលាខេត្ត ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមខ្លឹមសារសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ។

កំពង់ឆ្នាំង ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**ឈួរ ចន់ធឿន**

**ចម្លងជូន:**

- -ក្រសួងមហាផ្ទៃ
- -ក្រសួងមុខងារសាធារណៈ
- -ក្រុមប្រឹក្សាខេត្ត
- (ដើម្បីជូនជ្រាប)
- -ក្នុងប្រការ៤
- -ឯកសារ កាលប្បវត្តិ